# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២៨១២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការគ្រប់គ្រងមូលនិធិបម្រុងហិរញ្ញវត្ថុរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១** .-

អនុក្រឹត្យនេះ កំណត់អំពីវិធាននិងនីតិវិធីនៃការគ្រប់គ្រង "មូលនិធិបម្រុងហិរញ្ញវត្ថុរបស់រដ្ឋ" សរសេរជាអក្សរកាត់ថា "**ម.ហ.រ.**" ព្រមទាំងកំណត់គោលដៅប្រើប្រាស់មូលនិធិឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ដើម្បីរួមចំណែករក្សាគុល្យភាពហិរញ្ញវត្ថុ និងចីរភាពសេដ្ឋកិច្ចកម្ពុជា ជាពិសេស ក្នុងពេលជួបវិបត្តិសេដ្ឋកិច្ច ហិរញ្ញវត្ថុ ឬគ្រោះអាសន្នបន្ទាន់នានា។

**មាត្រា២** .-

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះសកម្មភាពទាក់ទងនឹងការគ្រប់គ្រង ការបោត់ចែង និងការប្រើប្រាស់ ម.ហ.រ.។

**មាត្រា៣** .-

វាក្យសព្ទសំខាន់ៗ ដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យ ដូចខាងក្រោម៖



ៗ

**-សំពៀតវិនិយោគ** សំដៅដល់ទំហំសរុបនៃការវិនិយោគរបស់ ម.ហ.រ. មានជាអាទិ៍ មូលបត្រ សាច់ប្រាក់ និងឧបករណ៍ហិរញ្ញវត្ថុនានា។

**-សន្ទនីយភាព** សំដៅដល់សមត្ថភាពក្នុងការបំប្លែង ទ្រព្យសកម្មនៅក្នុងសំពៀតវិនិយោគរបស់ ម.ហ.រ. ជាសាច់ប្រាក់បានជាបន្ទាន់ ដោយមិនមានការខាតបង់ ឬមានការខាតបង់តិចតួច។

**-ហានិភ័យ** សំដៅដល់ស្ថានភាពដែលអាចប្រឈមនឹងផលលំបាក ឬការខាតបង់ផ្សេងៗ ដែលអាចកើតមានឡើងក្នុងប្រតិបត្តិការចាត់ចែង និងវិនិយោគសំពៀតវិនិយោគរបស់ ម.ហ.រ.។

**-ហានិភ័យហិរញ្ញវត្ថុ** រួមមាន ១). ហានិភ័យទីផ្សារ បណ្តាលមកពីបម្រែបម្រួលអត្រាការប្រាក់, អត្រាប្តូរប្រាក់, និងតម្លៃទំនិញជាដើម, ២). ហានិភ័យឥណទាន បណ្តាលមកពីអ្នកបោះផ្សាយមូលបត្រ ឬ សមភាគីនៃការវិនិយោគដែលមាននៅក្នុងសំពៀតវិនិយោគរបស់ ម.ហ.រ. មិនអាចបំពេញលក្ខខណ្ឌតាមការសន្យា, និង ៣). ហានិភ័យសន្ទនីយភាព។

**-ហានិភ័យប្រតិបត្តិការ** សំដៅដល់ការប្រឈមនឹងការខាតបង់ដែលអាចបណ្តាលមកពីហានិភ័យបច្ចេកវិទ្យា អនិរន្តរភាពនៃ ម.ហ.រ. ហានិភ័យដំណើរការ និងហានិភ័យមនុស្សរួមមានកំហុសអចេតនា និងការក្លែងបន្លំ។

**-ហានិភ័យគតិយុត្ត** សំដៅដល់ហានិភ័យដែលបង្កឡើងដោយការផ្លាស់ប្តូរច្បាប់ ឬបទដ្ឋានគតិយុត្តទាំងក្នុងប្រទេស និងក្រៅប្រទេសជាពិសេសប្រទេសដែលពាក់ព័ន្ធនឹងការវិនិយោគរបស់ ម.ហ.រ.។

**-ហានិភ័យកេរ្តិ៍ឈ្មោះ** សំដៅដល់ការប៉ះពាល់កេរ្តិ៍ឈ្មោះរបស់ ម.ហ.រ. ដែលបង្កឡើងដោយព័ត៌មានពិតក្តី ឬមិនពិតក្តី ពាក់ព័ន្ធនឹងដំណើរប្រតិបត្តិការរបស់ ម.ហ.រ. ដែលអាចមានបច្ច័យលើផលចំណូលរបស់ ម.ហ.រ. ឬបាត់បង់ភាគីនៃការវិនិយោគ។

**-កម្រិតហានិភ័យដែលអាចទទួលយកបាន** សំដៅដល់បម្រែបម្រួលបរិមាណនៃកម្រិតហានិភ័យអតិបរមាដែលអាចទទួលយកបាន ដោយគិតគូរដល់វិធានការសមស្របដើម្បីកាត់បន្ថយហានិភ័យ។

## ជំពូកទី២

## ប្រភពធនធាន យន្តការសន្សំ និងគោលដៅប្រើប្រាស់

### មាត្រា៤ .-

ម.ហ.រ. មានប្រភពចំណូលពីៈ

-ចំណាយប្រចាំឆ្នាំនៃថវិកាថ្នាក់ជាតិ ក្នុងទំហំពី២(ពីរ)ភាគរយ ទៅ៤(បួន)ភាគរយនៃលទ្ធផលអនុវត្តចំណូលចរន្តថវិកាថ្នាក់ជាតិមួយឆ្នាំមុនឆ្នាំកំពុងអនុវត្តថវិកា ដែលត្រូវកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ

-អតិរេកដែលអាចកើតមានពីការអនុវត្តថវិកាថ្នាក់ជាតិប្រចាំឆ្នាំ ដែលត្រូវកំណត់ដោយច្បាប់ទូទាត់ថវិកា

-ប្រភពផ្សេងៗទៀត ដែលត្រូវកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុ រួមបញ្ចូលទាំងផលចំណេញនៃការប្រាក់ និងចំណូលដែលទទួលបានពីការប្រើប្រាស់ ម.ហ.រ. សម្រាប់ដាក់ជាប្រាក់បញ្ញើ និងការវិនិយោគ។

**មាត្រា៥ .-**

ម.ហ.រ. ត្រូវកត់ត្រាក្នុងគណនីទោលរតនាគារ។ សមតុល្យនៃ ម.ហ.រ. ត្រូវបានយោងបន្តពីមួយឆ្នាំទៅមួយឆ្នាំ។

ម.ហ.រ. ត្រូវរក្សាទុកនៅរតនាគារជាតិជាចាំបាច់ លើកលែងតែមានការអនុញ្ញាតដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៦ .-**

ថវិកានៅក្នុង ម.ហ.រ. អាចសន្សំតាមរយៈការដាក់ប្រាក់បញ្ញើនៅធនាគារ និងវិនិយោគរយៈពេលខ្លី មធ្យម និងវែង ដើម្បីរក្សាបាននូវតម្លៃនៃ ម.ហ.រ. ធៀបនឹងអតិផរណា, ធានាពិពិធកម្មនៃហានិភ័យ, និងរក្សាបាននូវចំណែកសន្ទនីយភាព ដែលអនុញ្ញាតឱ្យធ្វើការបើកប្រាក់យកមកប្រើប្រាស់បានទាន់ពេលដែលមានតម្រូវការបន្ទាន់ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ។

**មាត្រា៧ .-**

ម.ហ.រ. ត្រូវបានសន្សំទុកសម្រាប់គោលដៅនៃការធ្វើអន្តរាគមន៍ដោះស្រាយបញ្ហា ដែលមានសារៈសំខាន់ជាសារវន្ត នៅពេលដែលប្រទេសជាតិប្រឈមមុខនឹងវិបត្តិសេដ្ឋកិច្ច ហិរញ្ញវត្ថុ ឬគ្រោះអាសន្នបន្ទាន់នានា ជាអាទិ៍ ការឆ្លងរាលដាលនៃជំងឺកាចសាហាវ និងគ្រោះមហន្តរាយធម្មជាតិ។

## ជំពូកទី៣

## ក្របខ័ណ្ឌគ្រប់គ្រង

**មាត្រា៨ .-**

ម.ហ.រ. ត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់នាយករដ្ឋមន្ត្រី ដែលមានគណៈកម្មាធិការមូលនិធិបម្រុងហិរញ្ញវត្ថុរបស់រដ្ឋ សរសេរជាអក្សរកាត់ថា "**គ.ម.ហរ.**" ជាសេនាធិការ ក្នុងការគ្រប់គ្រង និងការចាត់ចែង ម.ហ.រ.។

គណៈកម្មាធិការមូលនិធិបម្រុងហិរញ្ញវត្ថុរបស់រដ្ឋ មានសមាសភាពដូចតទៅ៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| - ទេសាភិបាលធនាគារជាតិនៃកម្ពុជា | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១ រូប អនុប្រធានប្រចាំការ |
| - ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា | ១ រូប សមាជិក |



9

- ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ២ រូប សមាជិក

- ប្រធានលេខាធិការដ្ឋាន ១ រូប សមាជិក។

សមាសភាពជាក់ស្តែងរបស់ គ.ម.ហ.រ. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

គណៈកម្មាធិការមូលនិធិបម្រុងហិរញ្ញវត្ថុរបស់រដ្ឋ មានលេខាធិការដ្ឋានមូលនិធិបម្រុងហិរញ្ញវត្ថុរបស់រដ្ឋ សរសេរជាអក្សរកាត់ថា "**ល.ម.ហ.រ.**" ស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ ល.ម.ហ.រ. ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ សមាសភាពជាក់ស្តែងរបស់ ល.ម.ហ.រ. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៩ .-**

គណៈកម្មាធិការមូលនិធិបម្រុងហិរញ្ញវត្ថុរបស់រដ្ឋ មានតួនាទី និងភារកិច្ចដូចតទៅៈ

- កំណត់គោលនយោបាយនិងយុទ្ធសាស្ត្រគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ ម.ហ.រ.
- កំណត់គោលនយោបាយវិនិយោគ និងសេចក្តីណែនាំនៃការវិនិយោគ ម.ហ.រ.
- ពិនិត្យ និងសម្រេចលើគម្រោងវិនិយោគរយៈពេលខ្លី មធ្យម និងវែង
- ពិនិត្យ និងសម្រេចលើរបាយការណ៍ចំណូល ចំណាយរបស់ ម.ហ.រ.
- រាយការណ៍ចំណូល និងចំណាយ ជារៀងរាល់ឆ្នាំ ជូនរាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា។

**មាត្រា១០ .-**

គោលនយោបាយវិនិយោគ និងសេចក្តីណែនាំនៃការវិនិយោគ ព្រមទាំងនីតិវិធីនៃការចាត់ចែង និងការប្រើប្រាស់ ម.ហ.រ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការផ្តល់យោបល់ពី គ.ម.ហ.រ. ។

**មាត្រា១១ .-**

ការគ្រប់គ្រងហានិភ័យនិងប្រាក់ចំណូល ត្រូវមានចែងនៅក្នុងគោលនយោបាយវិនិយោគ និងសេចក្តីណែនាំនៃការវិនិយោគ ម.ហ.រ. ដោយមានការផ្តល់យោបល់ពី គ.ម.ហ.រ.។

**មាត្រា១២ .-**

គ.ម.ហ.រ. ត្រូវគោរពស្នើសុំគោលការណ៍អនុញ្ញាតពីនាយករដ្ឋមន្ត្រី ដើម្បីដកប្រាក់ពី ម.ហ.រ. មកប្រើប្រាស់សម្រាប់ការធ្វើអន្តរាគមន៍ដោះស្រាយបញ្ហា ក្នុងកាលៈទេសៈដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ និងជាកម្មវត្ថុនៃការអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអាណាប័កដើមខ្សែនៃ ម.ហ.រ. ក្នុងការបញ្ជាប្រតិបត្តិការចំណូល និងចំណាយ។



9

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា១៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងស្ថាប័ន ទេសាភិបាលធនាគារជាតិនៃកម្ពុជា និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៩កើត ខែ មិគសិរ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ ១២ ឆ្នាំ ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ